# តើអ្នកបានដឹង . . .

## អំពីសេវាកម្មនិងការឧបត្ថម្ភដូចតទៅនេះ
## សំរាប់ជីដូនជីតា និងសាច់ញាតិដែលចិញ្ចឹមបីបាច់ក្មេងឬទេ?



## អ្នកមិនមែនឯកោទេ!

ជីដូនជីតានឹងសាច់ញាតិផ្សេងទៀត មានចំនួនច្រើនជាង 35,000 នាក់ ដែលចិញ្ចឹមបីបាច់ក្មេងនៅក្នុងរដ្ឋវ៉ាស៊ីនតោន ។ ពត៌មានដែលរាយនៅខាងក្រោមនេះ គឺជាធនធាន, បំណាច់, និងសេវាឧត្ថម្ភផ្សេងៗគ្នា ដែលអាចមានសំរាប់អ្នកតាមរយៈ ក្រសួងសង្គមកិច្ចនិងសុខាភិបាល (DSHS) និងទីភ្នាក់ងារដទៃទៀត ។

## អ្នកនិងក្មេងនៅក្នុងការមើលថែទាំរបស់អ្នក អាចមានគុណសម្បត្តិសំរាប់ទទួល . . .

ជំនួយហិរញ្ញវត្ថុជាបន្តបន្ទាប់ តាមរយៈជំនួយសំរាប់មានក្មេងនៃកម្មវិធី TANF (កម្មវិធីជំនួយបណ្តោះអាសន្នសំរាប់គ្រួសារត្រូវការ) ។ មានតែប្រាក់ចំណូលនិងធនធានរបស់ក្មេងតែប៉ុណ្ណោះ ដែលគណនានៅក្នុងការកំណត់ពីលក្ខណសម្បត្តិ ។ សំរាប់ពត៌មានច្រើនថែមទៀត ចូលទៅអ៊ិនធើណែត **https://wws2.wa.gov/dshs/onlinecso/non_needy_relative_grant.asp** ។ ដើម្បីដាក់ពាក្យសុំ ចូរទាក់ទងទៅការិយាល័យបំរើ សហគមន៍នៅក្នុងតំបន់របស់អ្នក (CSO) ឬដាក់ពាក្យតាមបណ្តាញអ៊ិនធើណែតនៅ: **http://onlineapp.dshs.wa.gov** ។ ទូរស័ព្ទទៅលេខ 1-800-865-7801 ដើម្បីរកកន្លែង CSO ក្នុងតំបន់របស់អ្នក ។ អ្នកទទួលជំនួយ ជំនួយសំរាប់មានក្មេងនៃកម្មវិធី TANF អាចទទួលប្រាក់បន្ថែមម្តង សំរាប់ជួយក្នុងភាពបន្ទាន់អាសន្នចំពោះថ្លៃផ្ទះ ឬទឹកភ្លើងដែលត្រូវការ តាមរយៈកម្មវិធី Additional Requirements for Emergent Needs (កម្មវិធីតំរូវការបន្ថែម សំរាប់សេចក្តីត្រូវការបន្ទាន់អាសន្ន)(AREN) ។

ជំនួយផ្នែកពេទ្យ (ក៏ហៅទៀតថា ប័ណ្ណមេឌីខេដ ឬប័ណ្ណផ្នែកពេទ្យ) ដើម្បីធានារ៉ាប់រងផ្នែកពេទ្យ, ធ្មេញ, និងចំណាយលើផ្នែកសុខភាពខួរក្បាល ។ ក្មេងដែលនៅក្នុងការមើលថែទាំដោយសាច់ញាតិអាចទទួលជំនួយផ្នែកពេទ្យ ដោយមិនទទួលជំនួយសំរាប់មានក្មេងនៃកម្មវិធី TANF ។ ដើម្បីដាក់ពាក្យសុំ ចូរទាក់ទងការិយាល័យបំរើសហគមន៍របស់អ្នក ឬផ្ទុកក្រដាសពាក្យក្នុងកុំព្យូទ័រពីអ៊ិនធើណែត **http://www1.dshs.wa.gov/pdf/ms/forms/14_380.pdf** ។

ភាពបន្ទាន់អាសន្ន, ការឧបត្ថម្ភរយៈពេលខ្លីសំរាប់អ្នកមើលថែទាំសាច់ញាតិដែលគ្មានអាជ្ញាប័ណ្ណ តាមរយៈកម្មវិធីឧបត្ថម្ភបំរើដោយសាច់ញាតិ ។ មូលនិធិទាំងនេះគឺសំរាប់ក្មេងដែលដាក់ឲ្យថែទាំដោយនាយកដ្ឋានផ្នែកកុមារនិងគ្រួសារ (DCFS) និងគឺដើម្បីសម្រួល ឬថែរក្សាការទុកដាក់ឲ្យថែទាំនៃនាយកដ្ឋាន DCFS ។ ប្រាក់មូលនិធិអាចបង់សំរាប់គ្រឿងគុទ្ធ, សំលៀកបំពាក់, សម្ភារៈសិក្សា, ។ល។ ចូរទាក់ទងអ្នកធ្វើការនៃនាយកដ្ឋាន DCFS របស់អ្នក ។

ការឧបត្ថម្ភរយៈពេលខ្លីតាមរយៈកម្មវិធីការឧបត្ថម្ភចំពោះអ្នកមើលថែទាំដោយសាច់ញាតិ ។ មូលនិធិគឺសំរាប់អ្នកមើលថែទាំជាសាច់ញាតិ ដែលមិនចូលរួមនៅក្នុងកម្មវិធីប្រព័ន្ធសុខុមាលភាពកុមារ និងអាចបង់ប្រាក់សំរាប់ចំណីអាហារ, ថ្លៃផ្ទះ, សំលៀកបំពាក់, សម្ភារៈសិក្សា, ការបំរើផ្នែកច្បាប់, ជាដើម ។ល។ សំរាប់ពត៌មានច្រើនថែមទៀត ចូរទាក់ទងទៅការិយាល័យពត៌មានជរាជន និងជំនួយនៅក្នុងតំបន់របស់អ្នក ។ ដើម្បីរកទីកន្លែងការិយាល័យ ទូរស័ព្ទទៅការិយាល័យ Aging and Disability Service Administration (ការគ្រប់គ្រងសេវាជនចាស់ជរានិងពិការភាព) តាមលេខ 1-800-422-3263 ឬទៅមើលអ៊ិនធើណែត **http://www.adsa.dshs.wa.gov/Resources/clickmap.htm** ។

ជំនួយផ្នែកថែទាំក្មេង តាមរយៈកម្មវិធីមើលថែទាំក្មេងដែលទាក់ទងជាមួយការងារ (WCCC) ។ អ្នកមើលថែទាំសាច់ញាតិ ជាប្តីប្រពន្ធអាចមានគុណសម្បត្តិសំរាប់កម្មវិធី WCCC ទោះបីជាមានតែម្នាក់ធ្វើការក៏ដោយ ។ សំរាប់ពត៌មានកម្មវិធីនិងការដាក់ពាក្យសុំ ទៅមើលអ៊ិនធើណែត **https://wws2.wa.gov/dshs/onlinecso/WCCC.asp** ឬទាក់ទងទៅការិយាល័យបំរើសហគមន៍របស់អ្នកដោយផ្ទាល់ឬតាមទូរស័ព្ទ ។

នាយកដ្ឋានការមើលថែទាំកុមារនិងការសិក្សាបឋមវ័យនៃក្រសួង DSHS ក៏មានបើកកម្មវិធីមើលថែទាំក្មេងតាមរដូវ សំរាប់អ្នកធ្វើការផ្នែកកសិកម្មប្រចាំរដូវ និងកម្មវិធីមើលថែទាំក្មេងដែលគ្មានលំនៅ សំរាប់គ្រួសារដែលគ្មានផ្ទះបណ្តោះអាសន្ន (ឧ.ហ. រស់នៅតាមកន្លែងជម្រកបណ្តោះអាសន្ន, ក្នុងរថយន្ត, តង់, សួន, ផ្ទះរង់ចាំ, ឬជាមួយគ្រួសារ ឬមិត្តសំឡាញ់បណ្តោះអាសន្ន) ។ សំរាប់ពត៌មាននៃកម្មវិធី ទៅមើលអ៊ិនធើណែត **http://www1.dshs.wa.gov/esa/dccel/parents.shtml** ។ សំរាប់ពត៌មានអំពីកម្មវិធីមើលថែទាំក្មេងគ្មានលំនៅ អ្នកក៏អាចទាក់ទងទៅ Denise Halloran លេខ 360-725-4683 ។

កម្មវិធីការបំប៉នចំណីបន្ថែមពិសេស តាមរយៈកម្មវិធីក្រសួងសុខភាពមាតា, ទារក, និងកុមារ (WIC) ។ កម្មវិធី WIC ទទួលកុមារដែលមានអាយុនៅក្រោមប្រាំឆ្នាំ ដែលប្រាក់ចំណូលមានគុណសម្បត្តិ និងមានគ្រោះថ្នាក់ខ្វះការបំប៉នចំណី ។ សំរាប់ពត៌មានច្រើនថែមទៀត ទាក់ទងកម្មវិធី WIC តាមលេខ 1-800-841-1410 ឬអ៊ិនធើណែត **http://www.doh.wa.gov/cfh/WIC/default.htm** ។

ដោយមិនយកឬបន្ថយតំលៃម្ហូបអាហារ តាមរយៈកម្មវិធី National School Lunch/School Breakfast Programs and the Child and Adult Care Food Program (អាហារថ្ងៃត្រង់/ពេលព្រឹកនៅសាលារៀនជាតិ និងកម្មវិធីម្ហូបអាហារមនុស្សធំនិងកុមារ) (CACFP) ។ កម្មវិធី CACFP ផ្តល់អាហារពេលព្រឹក, អាហារថ្ងៃត្រង់, និងអាហារស្រស់ស្រូបជាច្រើនដង មុននិងក្រោយកម្មវិធីមើលថែទាំពេលថ្ងៃនៅសាលារៀន នៅតាមសាលារៀន សាធារណៈនិងឯកជនជាច្រើន ។ សំរាប់ពត៌មានច្រើនថែមទៀត ទាក់ទងទៅសាលារៀនក្នុងតំបន់របស់អ្នក ឬការិយាល័យនៃមណ្ឌលសិក្សាការអប់រំសាធារណៈ តាមលេខ 360-725-6200 ឬអ៊ិនធើណែត **http://www.k12.wa.us/childnutrition** ។

សេវាអន្តរាគមន៍បឋមវ័យ តាមរយៈកម្មវិធី Washington State Infant Toddler Early Intervention Program (អន្តរាគមន៍បឋមវ័យនៃក្មេងអាយុពីរឬបីឆ្នាំនៃរដ្ឋវ៉ាស៊ិនតោន) (ITEIP) ។ បើសិនជាអ្នកមើលថែក្មេងដែលមាន ពិការភាព ឬមានអារម្មណ៍អំពីការលូតលាស់របស់ក្មេង ពីអាយុកំណើតដល់បីឆ្នាំ ទូរស័ព្ទទៅកម្មវិធី Healthy Mothers/Healthy Babies (សុខភាពមាតា/សុខភាពទារក) លេខ 1-800-322-2588 (TTY 711) ។ សួររកឈ្មោះនៃអ្នកសម្របសម្រួលធនធានគ្រួសារ (FRC) នៅក្នុងសហគមន៍ក្នុងតំបន់អ្នក ។ អ្នកធ្វើការ FRC នឹងជួយអ្នកឲ្យដឹងថា តើក្មេងដែលអ្នកមើលថែទាំនោះមានគុណសម្បត្តិសំរាប់ទទួលសេវាអន្តរាគមន៍បឋមវ័យដែលឬទេ ។ សំរាប់ពត៌មានច្រើនថែមទៀត ទាក់ទងកម្មវិធី ITEIP តាមលេខ 360-725-3500 ឬអ៊ិនធើណែត **http://www1.dshs.wa.gov/iteip** ។

សេវាសំរាប់រោគវិនិច្ឆ័យបុគ្គលម្នាក់ៗជាមួយការលូតលាស់នៃពិការភាព និង/ឬការពន្យាការលូតលាស់ តាមរយៈនាយកដ្ឋានអភិវឌ្ឍន៍នៃភាពពិការ (DDD) នៃក្រសួង DSHS ។ សេវានិងការឧបត្ថម្ភនៃនាយកដ្ឋាន DDD គឺមានមូលដ្ឋានលើចំណូលចិត្ត, សមត្ថភាព, និងសេចក្តីត្រូវការនៃបុគ្គលម្នាក់ៗ ហើយនិងផ្សព្វផ្សាយនូវសកម្មភាព, ទម្លាប់, និងទំនាក់ទំនងទូទៅរៀងរាល់ថ្ងៃចំពោះប្រជាជនស្មើរតែទាំងអស់ ។ សំរាប់ពត៌មានច្រើនថែមទៀត មើលវ៉ិបសៃនៃនាយកដ្ឋាន DDD នៅ **http://www1.dshs.wa.gov/ddd/index.shtml** ។ លេខទូរស័ព្ទមិនយកថ្លៃសំរាប់ការិយាល័យតំបន់នៃនាយកដ្ឋាន DDD អាចរកឃើញនៅក្នុងអ៊ិនធើណែត **http://www1.dshs.wa.gov/ddd/contacts.shtml** ។

សេវាព្យាបាលអ្នកនៅក្រោមឥទ្ធិពលជាតិគីមី តាមរយៈនាយកដ្ឋាន Division of Alcohol and Substance Abuse (ការបំពានគ្រឿងស្រវឹង និងគ្រឿងញៀន) (DASA) នៃក្រសួង DSHS ។ សេវានៃនាយកដ្ឋាន DASA អាចត្រូវបង់ថ្លៃដោយប្រើប័ណ្ណពេទ្យ ហើយនាយកដ្ឋាន DASA មាន"មូលនិធិជួយពេលពិបាក" ដែលអាចជួយដល់អ្នកផ្តល់ការមើលថែទាំក្នុងការចំណាយផ្នែកធ្វើដំណើរនឹងការស្នាក់នៅពេលយុវជនស្ថិតក្នុងការព្យាបាល ។ សេវាព្យាបាលក៏អាចមានសំរាប់មនុស្សធំ ដែលជួបនឹងគោលការណ៍នៃប្រាក់ចំណូល ។ សំរាប់ពត៌មានច្រើនថែមទៀត ឬដើម្បីដាក់ពាក្យសុំសំរាប់សេវាបំរើ ចូរទាក់ទងបណ្តាញទូរស័ព្ទជំនួយគ្រឿងស្រវឹង/គ្រឿងញៀន 24 ម៉ោងក្នុងមួយថ្ងៃ តាមលេខ 1-800-562-1240 ។

ការបង្កើតបិតុភាព តាមរយៈនាយកដ្ឋានការឧបត្ថម្ភក្មេង (DCS) នៃក្រសួង DSHS ។ ការបង្កើតបិតុភាព ធ្វើឲ្យមានទំនាក់ទំនងផ្លូវច្បាប់រវាងឪពុកនិងកូន ដែលអាចជួយផ្តល់ប្រវត្តិផ្នែកពេទ្យនៃគ្រួសារ និងលក្ខណសម្បត្តិសំរាប់ជំនួយសន្តិសុខសង្គម ឬជំនួយអ្នកដែលមានកូននៅក្នុងបន្ទុកសំរាប់ជួយក្មេង ។ ការនេះក៏អាចជួយឪពុកឬម្តាយរបស់ក្មេង ពីព្រោះការបង់ប្រាក់ជំនួយដល់ក្មេងក្នុងបន្ទុក ក្នុងនាមនៃឪពុកឬម្តាយ គឺផ្តលឥណទានជាប្រាក់បង់ការឧបត្ថម្ភក្មេង ។ មើលនៅខាងក្រោមសំរាប់ពត៌មានធ្វើការទាក់ទង ។

ការទារប្រាក់ឧបត្ថម្ភក្មេង តាមរយៈនាយកដ្ឋានឧបត្ថម្ភក្មេង (DCS) នៃក្រសួង DSHS ។ នាយកដ្ឋាន DCS នឹងឲ្យអនុវត្តដីកាឧបត្ថម្ភក្មេងដែលមានដូចជាក្រិត្យលែងលះគ្នា, ឬនឹងបង្កើតដីកាឧបត្ថម្ភ បើសិនជាមានអ្នកណាម្នាក់ត្រូវការ ។ នាយកដ្ឋាន DCS រៀបចំកាតព្វកិច្ចឧបត្ថម្ភ ដោយយោលទៅតាមសមត្ថភាពរបស់ឪពុកឬម្តាយដែលអាចបង់បាន ។ នាយកដ្ឋាន DCS ក៏នឹងមានបំណងឲ្យមានឪពុកម្តាយធានារ៉ាប់រងសុខភាពឲ្យក្មេង បើសិនជាអាចមាន ។

សំរាប់ពត៌មានគ្រប់សេវានៃនាយកដ្ឋាន DCS ចូរមើលវ៉ិបសៃនៃនាយកដ្ឋាន DCS នៅ **http://www1.dshs.wa.gov/dcs/index.shtml** ឬទូរស័ព្ទលេខ 1-800-442-KIDS ។ អ្នកអាចដាក់ពាក្យសុំសំរាប់សេវាពីនាយកដ្ឋាន DCS ទោះបីជាអ្នកមិនទទួលជំនួយសាធារណៈក៏ដោយ ។ ការទទួលកម្មវិធី TANF ឬជំនួយផ្នែកពេទ្យ បង្កើតសំណុំរឿងនៃនាយកដ្ឋាន DCS ដោយស្វ័យប្រវត្តិ ។ បើសិនជាអ្នកភ័យខ្លាចថា សហប្រតិបត្តិការជាមួយនាយកដ្ឋាន DCS អាចត្រូវមានគ្រោះថ្នាក់ដល់អ្នកឬក្មេង ចូរទាក់ទងការិយាល័យបំរើសហគមន៍នៅក្នុងតំបន់របស់អ្នក ដើម្បីពិភាក្សាពី "មូលហេតុល្អ" ក្នុងការមិនសហប្រតិបត្តិការ ។

# ពត៌មានច្រើនថែមទៀតសំរាប់អ្នកផ្តល់ការមើលថែទាំជាសាច់ញាតិ . . .

ដើម្បីឲ្យដឹងពី "អ្នករកទិសដៅជាសាច់ញាតិ" ដែលអាចជួយដឹកនាំអ្នកទៅកាន់ប្រភពនៅក្នុងតំបន់របស់អ្នក ចូរទូរស័ព្ទលេខ 1-800-422-3263 ឬមើលវ៉ិបសៃត្រង់ Relatives as Parents (សាច់ញាតិជាឪពុកម្តាយ) នៅ **http://parenting.wsu.edu/relative/index.htm** ។ ចុចត្រង់ "Support Groups and Kinship Navigators" និងរួចហើយចុចត្រង់ "Find a Support Group or Kinship Navigator in your County" ។ ចូរកត់សំគាល់ថា អ្នករកទិសដៅជាសាច់ញាតិ មិនមានបំរើគ្រប់តំបន់នៃរដ្ឋទេ ។

ដើម្បីរកក្រុមឧបត្ថម្ភក្នុងតំបន់ជាមួយអ្នកមើលថែទាំជាសាច់ញាតិផ្សេងទៀត ចូរមើលវ៉ិបសៃត្រង់ Relative as Parents នៅ : **http://parenting.wsu.edu/relative/index.htm** ។ ចុចត្រង់ "Support Groups and Kinship Navigators" និងរួចហើយចុចត្រង់ "Find a Support Group or Kinship Navigator in your County" ។

សំរាប់ពត៌មានច្រើនថែមទៀតអំពីសេវានៃក្រសួង **DSHS** ដោយរួមទាំងការថែទាំដោយសាច់ញាតិ ចូរមើលវ៉ិបសៃ "No Wrong Door" នៅ : **http://www.dshs.wa.gov/basicneeds** ។

ដើម្បីរកមជ្ឈមណ្ឌលសុខភាពដែលផ្តល់ការមើលថែទាំផ្នែកពេទ្យនិងធ្មេញ សំរាប់ជនណាដែលធានារ៉ាប់រងដោយមេឌីខេដ ទៅមើលអ៊ិនធើណែត: **http://www.chs.hca.wa.gov** ។ ចុចត្រង់ "Find a CHS contracted clinic in Washington" នៅក្រោមអត្ថបទ "General Information" ។ បញ្ជីតារាងបញ្ជាក់ ថាតើមន្ទីរព្យាបាលទទួលអ្នកជម្ងឺនៃកម្មវិធីមេឌីខេដសំរាប់មើលថែទាំផ្នែកពេទ្យឬធ្មេញ ឬទាំងពីរ ។

អ្នកផ្តល់ការថែទាំជាសាច់ញាតិ ឥឡូវនេះអាចផ្តល់ការព្រមព្រៀងដែលបានប្រាប់ឲ្យដឹងតាមផ្លូវច្បាប់សំរាប់ការមើលថែទាំផ្នែកពេទ្យ នៅក្រោមល័ក្ខខ័ណ្ឌនៃច្បាប់ "Substitute House Bill 1281" ដែលអនុម័ត ដោយនីតិបញ្ញត្តិនៃរដ្ឋវ៉ាស៊ិនតោន នឹងមានសុពលភាពនៅថ្ងៃ 24 ខែកក្កដា ឆ្នាំ 2005 ។ សំរាប់ពត៌មានច្រើនថែមទៀត ចូរទាក់ទងទៅមជ្ឈមណ្ឌល "Women's Law Center" (មជ្ឈមណ្ឌលច្បាប់ផ្នែកស្ត្រី) ផ្នែកពត៌មាននិងការបញ្ជូនតាមបណ្តាញលេខ 206-621-7691 (TTY 206-521-4317) រៀងរាល់ថ្ងៃក្នុងអាទិត្យ នៅចន្លោះម៉ោង 9:30 ព្រឹក ដល់ម៉ោង 4:30 ល្ងាច និងចុងអាទិត្យនៅចន្លោះម៉ោង 5:30 និងម៉ោង 7:30 ល្ងាច ។ គំរូក្រដាសពាក្យនៃសេចក្តីប្រកាសក៏អាចផ្ទុកក្នុងកុំព្យូទ័រពីអ៊ិនធើណែត **www.washingtonlawhelp.org** ។

បើសិនជាអ្នកមានការពិបាកក្នុងការរកអ្នកមើលថែធ្មេញ និងត្រូវការជួយ, ចូរទាក់ទង Connie Mix-Clark នាយកគ្រប់គ្រងនៃកម្មវិធីផ្នែកធ្មេញ (DSHS & HCA Dental Program Manager) តាមអ៊ីមែល **clarkcl@dshs.wa.gov** ឬទូរស័ព្ទ 360-725-3455 (រាល់ថ្ងៃពុធ) ឬ 360-923-2753 (រាល់ថ្ងៃផ្សេងទៀត) ។

ដើម្បីរកទីភ្នាក់ងារសុខភាពខួរក្បាល ដែលទទួលយកប័ណ្ណផ្នែកពេទ្យ ទូរស័ព្ទលេខ 1-888-713-6010 ឬទៅអ៊ិនធើណែត: **http://www1.dshs.wa.gov/Mentalhealth/rsnmap.shtml** ។

អ្នកគាំទ្រឪពុកឬម្តាយនៅក្នុងនាយកដ្ឋានសុខភាពផ្លូវចិត្តនៃក្រសួង **DSHS** អាចត្រូវទាក់ទងតាមលេខ 1-800-446-0259 ext. 3 ។

សំរាប់ពត៌មាននិងការឧបត្ថម្ភក្នុងការចិញ្ចឹមបីបាច់ក្មេងដែលមានវិបលាសផ្លូវចិត្ត, ឥរិយាបថ, ឬជម្ងឺផ្លូវចិត្ត ចូរទាក់ទងទៅកម្មវិធី Statewide Action For Family Empowerment of Washington (សកម្មភាពទូទាំងរដ្ឋសំរាប់ ឲ្យអំណាចដល់គ្រួសារនៃរដ្ឋវ៉ាស៊ិនតោន) (SAFE WA) តាមលេខ 1-866-300-1998 ។

សំរាប់ពត៌មានអំពីប្រព័ន្ធយកក្មេងចិញ្ចឹមបីបាច់រក្សា និងសុខុមាលភាពកុមារ ចូរមើលវ៉ិបសៃ DSHS Children's Administration (ការគ្រប់គ្រងផ្នែកកុមារនៃក្រសួង DSHS) នៅ: **http://www1.dshs.wa.gov/ca/index.asp** ។

ពត៌មានអំពីប្រភពម្ហូបអាហារ ចូរទាក់ទង Family Food Line (បណ្តាញម្ហូបអាហារគ្រួសារ) ទូទាំងរដ្ឋ តាមលេខ 1-866-436-6392 ។ បណ្តាញម្ហូបអាហារគ្រួសារអាចផ្តល់ពត៌មានអំពីកម្មវិធីមូលដ្ឋានម្ហូបអាហារនៃរដ្ឋ, ម្ហូបអាហាររដូវក្តៅសំរាប់ក្មេងដោយមិនយកថ្លៃ, ឃ្លាំងម្ហូបអាហារក្នុងតំបន់, និងកម្មវិធីបំប៉នចំណីនៃផ្សារកសិករផ្នែកមនុស្សចាស់ ។

បណ្តាញទូរស័ព្ទ **Healthy Mothers Healthy Babies** (សុខុមាលភាពមាតាសុខុមាលភាពទារក) ផ្តល់ពត៌មាននិងការបញ្ជូនទៅក្នុងទំហំនៃសុខភាពដ៏ទូលំទូលាយ និងសេវាសង្គមកិច្ច ដែលទាក់ទងទៅនឹងការបីបាច់ថែរក្សាក្មេងទាំងគ្រប់អាយុទាំងអស់ ។ ប្រធានបទនៃផលប្រយោជន៍ចំពោះអ្នកផ្តល់ការមើលថែរក្សាជាសាច់ញាតិ រួមទាំងការធានារ៉ាប់រងសុខភាព, ការបំប៉នចំណី, ការចាក់ថ្នាំការពាររោគ, ការថែទាំក្មេង, ការធ្វើឲ្យក្មេងល្អតលាស់, ក្មេងដែលត្រូវការសេវាពិសេស, និងការឧបត្ថម្ភដល់ឪពុកឬម្តាយ/បងប្អូនបង្កើត ។ ទូរស័ព្ទលេខ 1-800-322-2588 (TTY 711) ឬទៅអ៊ិនធើណែត : **http://www.hmhbwa.org** ។

ឱកាសនៃការហ្វឹកហ្វឺន សំរាប់សាច់ញាតិ និងឪពុកម្តាយចិញ្ចឹមបីបាច់ ដែលមានបញ្ហាទាក់ទងនឹងបញ្ហាចរិយានោះ គឺបានផ្តល់ឲ្យដោយ Resource Family Training Institute (ស្ថាប័នហ្វឹកហ្វឺន ធនធានគ្រួសារ) ។ ចូរទាក់ទង Department of Licensed Resources Regional Training Coordinator (អ្នកសម្របសម្រួលការហ្វឹកហ្វឺននៃក្រសួងធនធានអាជ្ញាប័ណ្ណតំបន់) ឬមើលអ៊ិនធើណែត **http://fosterparent.dshs.wa.gov** ។ ចុចត្រង់ "Ongoing Training" ។

## ការបោះពុម្ពផ្សាយដោយមិនយកថ្លៃ . . .

សាច់ញាតិដូចជាឪពុកម្តាយៈ ប្រភពការណែនាំសំរាប់សាច់ញាតិដែលចិញ្ចឹមបីបាច់ក្មេងក្នុងរដ្ឋវ៉ាស៊ិនតោន (DSHS 22-996x) គឺជាការណែនាំទូទៅ សំរាប់គ្រប់អ្នកផ្តល់ការមើលថែទាំជាសាច់ញាតិ ។ ដើម្បីបញ្ជាសុំគ្រប់ក្រដាសផ្សាយពត៌មាននៃក្រសួង DSHS ចូរទៅអ៊ិនធើណែតៈ **www.prt.wa.gov** និងចុចត្រង់ "General Store" ឬទូរស័ព្ទទៅក្រសួងរោងពុម្ព តាមលេខ 360-586-6360 ។

ការណែនាំសាច់ញាតិចំពោះសេវាសុខុមាលភាពក្មេង (DSHS 22-492x) គឺជាពិសេសសំរាប់អ្នកផ្តល់ការមើលថែទាំជាសាច់ញាតិ ដែលចូលរួមជាមួយប្រព័ន្ធសុខុមាលភាពកុមារ ។

ការណែនាំរបស់ឪពុកឬម្តាយ ចំពោះប្រព័ន្ធសុខភាពខួរក្បាលសាធារណៈ គឺជាកូនសៀវភៅដែលបានសរសេរដោយមាតាបិតាទៅមាតាបិតា ។ ដើម្បីបញ្ជាសុំ ចូរទូរស័ព្ទលេខ 1-800-446-0259, លេខបន្ត 3 ។

ជំរើសនានាសំរាប់ជីដូនជីតា និងអ្នកផ្តល់ការមើលថែទាំដទៃផ្សេងទៀតមិនមែនជាមាតាបិតាៈ ការណែនាំផ្នែកច្បាប់សំរាប់រដ្ឋវ៉ាស៊ិនតោន គឺអាចមានដោយមិនយកថ្លៃសំរាប់អ្នកចិញ្ចឹមបីបាច់ក្មេងជាសាច់ញាតិ ដែលបានចូលរួមនៅក្នុងស្ថានការផ្នែកច្បាប់ ។ ពុំដូច្នេះទេ ក្រដាសការណែនាំអាចត្រូវទិញដោយទូរស័ព្ទទៅមជ្ឈមណ្ឌល Northwest Women's Law Center (មជ្ឈមណ្ឌលច្បាប់សំរាប់ស្ត្រីតំបន់ពាយព្យ) តាមលេខ 206-682-9552 ។

## សំនួរ ?

បើសិនជាអ្នកមានសំនួរអំពីពត៌មាននេះ សូមទាក់ទង Barbara Bofinger, ការិយាល័យ Children's Administration (ការគ្រប់គ្រងកុមារ) តាមអ៊ីមែល BOBA300@dshs.wa.gov, ទូរស័ព្ទលេខ (360) 902-7986; Tom Berry ការិយាល័យ Economic Services Administration (ការគ្រប់គ្រងសេវាសេដ្ឋកិច្ច) តាមអ៊ីមែល berrytj@dshs.wa.gov, ទូរស័ព្ទលេខ (360) 725-4617; ឬ Hilari Hauptman, ការិយាល័យ Aging and Disability Services Administration (ការគ្រប់គ្រងជនចាស់ជរានិងពិការភាព) តាមអ៊ីមែល haupthp@dshs.wa.gov, ទូរស័ព្ទលេខ 1-800-422-3263 ។

Find more kinship resources at:
**www1.dshs.wa.gov/kinshipcare**



Washington State
Department of Social & Health Services
DSHS 22-1120 CA (Rev. 9/06)
CAMBODIAN